**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យព្រះនាងម៉ារីជាមាតាព្រះសហគមន៍**
**អរីយ្យក្សត្រថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨**
*ព្រះនាងម៉ារីជាម្ដាយនៃព្រះសហគមន៍*

អត្ថបទទី១៖ យក ៣,១៣-១៨
ដំណឹងល្អ៖ មក ៩,១៥-២៩

បងប្អូនជាទីស្រឡាញ់!

ព្រះសហគមន៍មើលព្រះនាងម៉ារីជាម្ដាយនៃយើងផង ជាម្ដាយនៃព្រះជាម្ចាស់ផង ជាម្ដាយរបស់ព្រះសហគមន៍ផង។ ប៉ុន្តែឆ្នាំនេះ សម្ដេចប៉ាបបានសម្រេចចិត្តជាផ្លូវការ ព្រះសហគមន៍មានម្ដាយ គឺព្រះនាងម៉ារី។

ដូច្នេះថ្ងៃនេះ ព្រះសហគមន៍ណែនាំឲ្យយើងគោរពព្រះនាងម៉ារី ជាម្ដាយនៃព្រះសហគមន៍។ មូលហេតុអ្វី ដែលយើងអាចទទួលស្គាល់ថាព្រះនាងម៉ារីជាម្ដាយរបស់ព្រះសហគមន៍? តាមពិតព្រះនាងម៉ារីទទួលឋានៈជាម្ដាយពីរដង ខុសពីម្ដាយទាំងអស់។ លើកទីមួយ ក្នុងពេលដែលទេវទូតកាព្រីអែលបានប្រាប់ព្រះនាងម៉ារី "**នៅពេលនេះព្រះជាម្ចាស់បានជ្រើសរើសនាង ដើម្បីធ្វើជាមាតារបស់ព្រះយេស៊ូ**" និងនៅពេលដែលព្រះនាងម៉ារីបានឆ្លើយថា "**ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គចុះ**"។ នៅពេលនោះ ព្រះនាងម៉ារីបានទទួល ជីវិតជាម្ដាយតួនាទីជាម្ដាយ ដោយឯកភាពឲ្យមានផ្ទៃពោះ ដើម្បីទទួលជីវិតដំបូងគឺព្រះយេស៊ូផ្ទាល់ដែលជាបុត្រាជាទីស្រលាញ់របស់ព្រះជាម្ចាស់។ ព្រះនាងម៉ារីទទួលតួនាទីជាម្ដាយលើកទី២ នៅពេលព្រះនាងម៉ារីនៅក្បែរឈើឆ្កាង នៅពេលនោះព្រះយេស៊ូមើលព្រះនាងម៉ារីនិងលោកយ៉ូហាន ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា "**នេះជាកូនរបស់នាង**" ហើយនិយាយទៅលោកយ៉ូហាន "**នេះជាម្ដាយរបស់អ្នក**"។ លោកយ៉ូហាន នៅពេលនោះមិនមែនតែជាសាវ័កម្នាក់ ប៉ុន្តែលោកយ៉ូហានជាតំណាងក្រុមគ្រីស្តទូតទាំងអស់។

ដូច្នេះ ព្រះសហគមន៍បានកើតឡើង គឺនៅពេលដែលព្រះយេស៊ូបានត្រាស់ហៅ ក្រុមគ្រីស្តទូតទាំង១២នាក់ ដើម្បីដើរតាមព្រះយេស៊ូ។ យើងមានលោកម៉ាថាយ លោកថូម៉ាស លោកភីលីព លោកបាថូឡូមេ លោកសិលា លោកយ៉ូហាន លោកយូដា លោកយូដាសអេស្ការីយ៉ូត។ ទាំង១២រូប ទៅជាពូជដំបូងនៃព្រះសហគមន៍ ដើម្បីធ្វើដំណើរជាមួយព្រះយេស៊ូ ដើម្បីចាប់ផ្តើមស្គាល់ព្រះយេស៊ូ ដើម្បីទទួលការអប់រំពីព្រះយេស៊ូ។ នៅក្នុងបីឆ្នាំ ដែលគេធ្វើដំណើរជាមួយព្រះយេស៊ូ បន្តិចម្ដងៗគេរៀនអំពីតួនាទីថ្មីរបស់គេ។ តួនាទីគឺអ្វី? ដូចព្រះយេស៊ូមានព្រះបន្ទូលទៅលោកសិលា "**លែងទៅជានេសាទត្រី ចាប់ពីពេលនេះតទៅគឺនេសាទមនុស្ស**" មានន័យថាប្រមូល

មនុស្ស ប៉ុន្តែដោយមានព្រះជាម្ចាស់។ នេះជាពូជដំបូងនៃព្រះសហគមន៍ ជាក្រុមគ្រីស្តទូតដែលធ្វើដំណើរជាមួយព្រះយេស៊ូ ប្រមូលមនុស្សមានន័យថាប្រជាជនទាំងអស់ អ្នកក្រីក្រ អ្នកជំងឺ អ្នកពិការអ្នកខ្វាក់ ដោយសារគេចង់ទទួលសេចក្តីសង្ឃឹម។ ព្រះសហគមន៍ដំបូង គឺក្រុមគ្រីស្តទូតដើរជាមួយព្រះយេស៊ូ និងប្រមូលមហាជន ដោយនាមព្រះជាម្ចាស់ដើម្បីទទួលជីវិត។

នៅក្បែរឈើឆ្កាង យើងនៅសល់តែលោកយ៉ូហាន ដែលជាតំណាងក្រុមគ្រីស្តទូតទាំងអស់ ដែលសាវ័កដ៏ជាទីស្រលាញ់របស់ព្រះយេស៊ូ។ គ្រីស្តទូតផ្សេងៗដូចជាគេភ័យខ្លាច លោកសិលាគាត់ក្បត់ព្រះយេស៊ូហើយ លោកយ៉ូដាសអេស្ការីយ៉ុតក្បត់ចង់សម្លាប់ព្រះយេស៊ូ បានសម្លាប់ខ្លួនឯង និងគ្រីស្តទូតឯទៀតៗអត់ដឹងគេរត់ទៅណាដោយសារគេភ័យ ប៉ុន្តែលោកយ៉ូហានដែលជាគ្រីស្តទូតជាទីស្រលាញ់នៅក្បែរឈើឆ្កាង ជាមួយមាតារបស់ព្រះអង្គ។ ដោយសារម្តាយអត់ដែលលះបង់ចោលកូនទេ ទោះបីកូនមានបញ្ហាណាក៏ដោយ ហើយនៅពេលនោះយើងឃើញព្រះយេស៊ូដែលកំពុងសោយទិវង្គត ម្តាយដែលកំពុងរងទុក្ខលំបាកយ៉ាងធំណាស់។ ម្តាយតើមានអ្វីដែលយ៉ាប់ជាងមើលឃើញកូនផ្ទាល់ខ្លួនដែលកំពុងស្លាប់ និងនៅពេលនោះព្រះយេស៊ូមានព្រះបន្ទូល "**យ៉ូហានអើយ! យ៉ូហានជាកូនរបស់ម្តាយ ខ្ញុំឲ្យម៉ែខ្ញុំហើយ**"។

ក្រុមគ្រីស្តទូតជាពូជនៃព្រះសហគមន៍ នៅពេលនោះព្រះយេស៊ូបានប្រទានព្រះនាងម៉ារីទៅជាម្តាយនៃព្រះសហគមន៍ ទៅជាម្តាយនៃក្រុមគ្រីស្តទូតដែលបានចាប់ផ្តើមធ្វើដំណើរជាមួយព្រះយេស៊ូ ដោយចាប់ផ្តើមប្រមូលប្រជាជន ដោយសារព្រះសហគមន៍ជាក្រុមគ្រីស្តបរិស័ទ ជាក្រុមប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលព្រះជាម្ចាស់ប្រមែរប្រមូល ដើម្បីកោតសរសើរព្រះអង្គ។

ព្រះនាងម៉ារី នៅពេលនោះទទួលតួនាទីជាម្តាយលើកទី២ ដោយធ្វើជាម្តាយនៃព្រះសហគមន៍ ម្តាយនៃព្រះជាម្ចាស់ ម្តាយនៃព្រះសហគមន៍។ ព្រះសហគមន៍គឺយើង ព្រះសហគមន៍បានកើតឡើង នៅពេលព្រះយេស៊ូប្រមូលក្រុមគ្រីស្តទូត។ ព្រះសហគមន៍ បានកើតឡើងយ៉ាងរឹងមាំនៅពេលនៅពេលព្រះវិញ្ញាណដ៏វិសុទ្ធយាងមក។ ពេលព្រះយេស៊ូ សោយទិវង្គតហើយ ក្រុមគ្រីស្តទូតគេកំពុងអស់សង្ឃឹមហើយ ទោះបីគេបានឃើញព្រះយេស៊ូបង្ហាញខ្លួនប៉ុន្មានដង ព្រះយេស៊ូបានឡើងស្ថានបរមសុខដោយថា ធ្វើពិធីជ្រមុជទឹកដោយនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ប៉ុន្តែក្រុមគ្រីស្តទូតហ្នឹងគេមិនសូវយល់ គេត្រូវការធ្វើអ្វី? ប្រកាសដំណឹងល្អយ៉ាងម៉េច? ទៅដាច់ស្រយាលនៃផែនដីយ៉ាងណា? គេអត់មានសេចក្តីក្លាហាន គេភ័យដល់កំពូលដោយសារពេលព្រះយេស៊ូឡើងស្ថានបរមសុខហើយ គេមិនបានចោលព្រះសហគមន៍ដំបូងដែលគេបានទទួល គេសុខចិត្តអធិដ្ឋាន គេសុខចិត្តជួបជុំគ្នា គេសុខចិត្តធ្វើពិធីកាច់នំប៉័ង ដូចព្រះយេស៊ូបានណែនាំឲ្យគេធ្វើ។ ប៉ុន្តែគេធ្វើនៅក្នុងបន្ទប់តូចមួយ ដែលមានបង្អួចតូចមែនទែន នៅ

ក្នុងផ្លូវស្ងាត់មែនទែន ដែលមានទ្វារតូចមែនទែន ហើយគេបិទទាំងអស់ជិតៗ ដោយសារគេភ័យ ។ នៅក្នុងក្រុមនេះ មានក្រុមគ្រីស្តទូត និងមាននាងម៉ារីមាតារបស់ព្រះយេស៊ូ និងបងប្អូនរបស់ព្រះអង្គទៀត។

រំពេចនោះ គេលឺសំលេងខ្យល់បក់ អណ្តាតភ្លើងចុះពីលើ ព្រះវិញ្ញាណដ៏វិសុទ្ធមកហើយ។ រំពេចនោះ ទ្វារបើកចំហរ និងបង្អួចនីមួយៗបើកអស់ហើយ រំពេចនោះគេហ៊ានចេញទៅតាមផ្លូវ ដោយសារថ្ងៃដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមក គឺថ្ងៃបុណ្យ៥០ គឺគេនឹករលឹកថ្ងៃដែលលោកម៉ូសេទទួលវិន័យ១០ប្រការនៅភ្នំពីព្រះជាម្ចាស់ ហេតុនេះហើយគេមកពីគ្រប់ទិស គ្រប់កន្លែងនៅក្នុងស្រុកកាលីឡេ ស្រុកយូដាដើម្បីធ្វើបុណ្យនៅព្រះវិហារក្រុងយេរូសាឡឹម។ មនុស្សច្រើនណាស់នៅតាមផ្លូវ ប៉ុន្តែរំពេចនោះនៅពេលគេទទួលព្រះវិញ្ញាណដ៏វិសុទ្ធ គេហ៊ានចេញដើម្បីប្រកាស អ្វីដែលព្រះយេស៊ូណែនាំឲ្យប្រកាសគឺ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងព្រះនាងម៉ារីនៅជាមួយគេ។ នាងម៉ារីនៅជាមួយគេ ព្រះសហគមន៍ត្រូវការមានមាតាមួយ ដើម្បីថែរក្សា យកចិត្តទុកដាក់ ផ្តល់ភាពកក់ក្តៅ មាតាដើម្បីធ្វើជាម្ចាស់ផ្ទះ មាតាដែលដឹងអំពីទុក្ខលំបាក និងទុក្ខវេទនារបស់កូន មាតាដែលចាប់អារម្មណ៍អំពីកូនម្នាក់ៗ។ ជាមូលហេតុ យើងមានអំណរសប្បាយថ្ងៃនេះណាស់ ដោយសារយើងដឹងថាព្រះសហគមន៍របស់យើង មិនមែនតែជាបូជាចារ្យដែលដឹកនាំ ប៉ុន្តែមាតារបស់ព្រះជាម្ចាស់ទៅជាមាតារបស់ព្រះសហគមន៍ មានន័យថាជាមាតារបស់យើងទាំងអស់គ្នា ដោយសារយើងជាព្រះសហគមន៍ ដែលជាព្រះកាយព្រះគ្រីស្ត។ ហេតុនេះហើង យើងមានម្តាយរបស់យើង ដែលថែទាំរក្សា លើកទឹកចិត្ត ផ្តល់ភាពកក់ក្តៅ ចាប់អារម្មណ៍ ដឹងអំពីអារម្មណ៍ទឹកចិត្តរបស់កូន ដឹងអំពីទុក្ខលំបាករបស់កូន មិនដែលចោលកូនទោះបីកូនធ្វើខុសក៏ដោយ វង្វេងផ្លូវក៏ដោយ ម្តាយមិនដែលចោលកូនទេ។ ម្តាយដែលចោលកូន គឺម្តាយអត់គ្រប់ទឹក ប៉ុន្តែម្តាយដែលគ្រប់ទឹកមិនចោលកូនទេ។ ម្តាយមានកូននៅក្នុងផ្ទៃពោះ កូននិងម្តាយស្គាល់គ្នាណាស់ ស្គាល់ក្លិន ស្គាល់សំលេង។ ទោះបីងងឹតភ្នែក ទំនាក់ទំនងជាមួយម្តាយមានអស់ហើយ ម្តាយមានទំនាក់ទំនងជាមួយកូនអស់ហើយ។ ហេតុនេះហើយ ម្តាយរបស់ព្រះសហគមន៍ គឺព្រះនាងម៉ារី ស្គាល់យើងរៀងៗខ្លួន ស្គាល់ក្លិនយើង ស្គាល់អារម្មណ៍យើង ស្គាល់ទឹកចិត្តយើង ស្គាល់កម្លាំងយើង ស្គាល់ភាពខ្សោយរបស់យើង ស្គាល់ទាំងអស់។

ថ្ងៃនេះ យើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់ព្រះនាងម៉ារីដែលណែនាំឲ្យព្រះសហគមន៍របស់យើងរីកចម្រើនទៅមុខ។ ព្រះនាងម៉ារីដើរនៅខាងមុខយើង មិនមែនដើម្បីឲ្យយើងពិបាក ប៉ុន្តែដើម្បីឲ្យយើងខិតខំ ដើរជាមួយក្រុមគ្រីស្តទូត ដើរនៅក្នុងព្រះសហគមន៍ តស៊ូនៅក្នុងជីវិត។ ព្រះនាងម៉ារី មានវត្តមាននៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ នៅថ្ងៃទី១៥ ខែ

សីហា យើងគោរពព្រះនាងម៉ារីចូលនៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយឡើងទៅស្ថានបរមសុខតែម្តង។ ព្រះនាងម៉ារី ជាមាតារបស់ព្រះជាម្ចាស់បានទទួលភាពដ៏វិសុទ្ធដ៏ពេញលក្ខណៈពីព្រះជាម្ចាស់អស់ហើយ។ ដូច្នេះព្រះនាងម៉ារី មានដៃមួយអស់ហើយនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដ៏ពេញលក្ខណៈ។ ព្រះនាងម៉ារីមានដៃមួយទៀតនៅលើផែនដីនេះ ដើម្បីធ្វើដំណើរជាមួយយើង ដើម្បីចាប់ដៃយើង ចាប់ដៃកូនឲ្យកូនខិតខំទៅមុខ ដោយមានភាពកក់ក្តៅលើកទឹកចិត្ត ដោយមានភាពណែនាំឲ្យយើងស្រួលនៅក្នុងចិត្ត ដើម្បីលាងរបួសនិងទុក្ខលំបាកដែលយើងមាននៅក្នុងជីវិតរបស់យើង។ ហេតុនេះហើយ យើងត្រូវមើលព្រះនាងម៉ារីបីដូចជានៅកណ្តាលរវាងព្រះជាម្ចាស់ និងយើងដែលជាមនុស្សសាមញ្ញធម្មតា ដែលទន់ខ្សោយ ដែលមានទុក្ខលំបាកច្រើន។ ប៉ុន្តែយើងមានម្តាយដែលចាប់ដៃ ធ្វើដំណើរបន្តិចៗដើម្បីឲ្យយើងចេះដើរ ចេះនិយាយ ញ៉ាំឆ្អែត កក់ក្តៅមិនរងារ កុំឲ្យយើងយំតែញញឹមជានិច្ច។ នេះជារបៀបដែលម្តាយធ្វើជាមួយកូនដ៏ដែត និងទោះបីជាម្តាយមានអាយុ៧០ឬ៨០ឆ្នាំ កូនអាយុ៥០ឬ៦០ឆ្នាំ ក៏ម្តាយនៅមើលឃើញកូនអាយុ២ឬ៣ឆ្នាំដដែលៗ។ នេះជារបៀបម្តាយ ជារបៀបព្រះនាងម៉ារីជាមួយយើង ដើម្បីការពារថែរក្សា និងលើកទឹកចិត្តយើង។

ដូច្នេះនៅលើផែនដី ប្រហែលយើងបាត់បង់ម្តាយរបស់យើងអស់ហើយ ទៅស្ថានបរមសុខឬស្លាប់ហើយ ប៉ុន្តែយើងដឹងថាយើងមានម្តាយមួយគឺព្រះនាងម៉ារី ដែលបន្តធ្វើដំណើរជាមួយយើងជានិច្ច។ ម្តាយនៃព្រះសហគមន៍ ហើយយើងទាំងអស់ជាព្រះសហគមន៍ មិនមែនតែក្រុមគ្រីស្តទូត មិនមែនតែបូជាចារ្យ ប៉ុន្តែយើងជាគ្រីស្តបរិស័ទទាំងអស់ យើងជាព្រះសហគមន៍។ ដូច្នេះថ្ងៃនេះ យើងអរព្រះគុណព្រះជាម្ចាស់ដែលបានប្រទានព្រះនាងម៉ារី ដែលជាម្តាយរបស់យើងដែលធ្វើដំណើរជាមួយយើង ដើម្បីឲ្យយើងពោរពេញដោយភាពកក់ក្តៅ និងពោរពេញដោយក្តីស្រលាញ់ពីម្តាយ ដើម្បីប្រកាសដំណឹងល្អ។ ពិតមែន ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ឲ្យយើងរួមគ្នាយើងមានអំណរសប្បាយ ដោយសារម្តាយធ្វើដំណើរជាមួយយើង ហើយណែនាំបន្តិចៗយើងចូលក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ អាម៉ែន៕